ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែវិច្ឆិកា

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣។

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣៥រូប និងតាមប្រព័ន្ធអនឡាយចំនួន៣៣រូប សរុបចំនួន៦៨រូប។

**៤. របៀបវារៈ៖**

៤.១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២- បទបង្ហាញស្តីពី "របាយកាណ៍វឌ្ឍនភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២៣" បង្ហាញដោយ ឯកឧត្តមវេជ្ជ. ឈា សិទ្ធិ អគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងៃអេដស៍ ។

៤.៣-បទបង្ហាញស្តីពី "សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ទូលំទូលាយ និងជាពហុវិស័យលើកទី៦" បង្ហាញដោយ **លោកវេជ្ជបណ្ឌិត ទា ផលី** ទីប្រឹក្សាបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤.៤- សេចក្តីព្រាងស្តីពីគោលការណ៍ណែនាំ ស្តីពីយន្តការរាយការណ៍ការឆ្លើយតបនឹងការមាក់ងាយ និងការរើសអើង បង្ហាញដោយ **លោក អ៊ឹង ប៉ូលីន** ទីប្រឹក្សាគាំទ្រសហគមន៍ នៃអង្គការ UNAIDS។

៤.៥- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជំងឺអេដស៍។

៥. លទ្ធផល ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសវិច្ឆិកា ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះ សំខាន់លើយុទ្ធវិធីជំរុញខ្លាំងក្លាការងារបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ។

កិច្ចប្រជុំនេះបានផ្តោតលើវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៣ និងទិសដៅបន្ត។ ជាលទ្ធផលនៃកិច្ចប្រជុំ បង្ហាញឱ្យឃើញថា៖

**៥.១ កាលានុវត្តភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា**

- ឆ្នាំ២០១៧ កម្ពុជាសម្រេចគោលដៅ ៩០-៩០-៩០ បីឆ្នាំមុនកាលកំណត់របស់អង្គការសហប្រជាជាតិ (២០២០)និងកំពុងស្ថិតលើដំណើរផ្លូវត្រូវក្នុងការឆ្ពោះទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ ២០២៥។
- អង្គការ UNAIDS ចេញផ្សាយកាលពីឆ្នាំ២០២១ អត្រាគ្របដណ្តប់នៃសេវាព្យាបាលអេដស៍នៅកម្ពុជា មានអត្រាខ្ពស់ជាងគេនៅតំបន់អាស៊ីប៉ាស៊ីហ្វិក គឺខ្ពស់ជាងប្រទេសថៃ ប្រទេសចិន និងប្រទេសវៀតណាម។
- ជាប្រទេសទី១ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលបានរៀបចំវាយតម្លៃភាពរួចរាល់ក្នុងការធ្វើអន្តរកាល (Transition Readiness Assessment) ផែនទីចង្អុលផ្លូវសម្រាប់និរន្តភាព (Sustainable Roadmap)នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- មានយន្តការឆ្លើយតបនឹងមេរោគមេរោគអេដស៍ និងជំងឺអេដស៍ ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ
- មានផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ ឆ្នាំ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រជាតិលើកទី៦ (២០២៤-២០២៨)។
- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានយល់ព្រមឱ្យរៀបចំក្រុមការងារបច្ចេកទេសតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍ នៅកម្ពុជា ឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ ២០២៣-២០២៨។

**៥.២ ក្រោមមគ្គុទេសភាព របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន កាកបាទក្រហមកម្ពុជា និងក្រុមការងារតេស្សរជនផ្តើមថ្នាក់ជាតិ ក្នុងរយៈពេល១០ខែ (មករា ដល់ តុលា) ឆ្នាំ ២០២៣នេះ សម្រេចបាន៖**

- ទិវាជាតិសុខភាពមាតាទារកនិងកុមារ ថ្ងៃទី២១ខែកុម្ភៈឆ្នាំ២០២៣ ក្រោមប្រធានបទ "រួមគ្នាពង្រឹងសេវាសុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ យុវវ័យ និងអាហារូបត្ថម្ភ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយ ចិរភាពនៃឆ្នាំ២០៣០" និងទី២ ទិវាធូបអន្តរជាតិ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ ក្រោមប្រធានបទ "រួមគ្នាជាថ្មី : ពីភស្តុតាងជាក់លាក់ ទៅការអនុវត្តពិតប្រាកដ"។
- សហការផលិត និងផ្សព្វផ្សាយកម្មវិធីឥស្សរជនឆ្នើមថ្នាក់ជាតិបានចំនួន១០។
- អប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង អំពីសុខភាពមាតា ទារក និងកុមារបានចំនួន៨,១៥៣នាក់ និងអំពីជំងឺអេដស៍បានចំនួន៣,៤៦០នាក់។
- ផ្តល់អំណោយមនុស្សធម៌ជូនស្ត្រី/កុមារបានចំនួន៣,៤៩៤នាក់ និងអ្នកផ្ទុកមេរោគអេដស៍បានចំនួន១,៨៨៩នាក់។
- ផលិត និងផ្សព្វផ្សាយព្រឹត្តិបត្តិព័ត៌មានឥស្សរជនបាន៣ពាន់ច្បាប់។
- ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា បានសម្រេចនូវគោលដៅជាតិចំនួន២រួចហើយ ក្នុងចំណោមគោលដៅជាតិទាំង៣ (៩៥-៩៥-៩៥ ក្នុងឆ្នាំ២០២៥) ដោយសម្រេចបាន ៨៦% សម្រាប់គោលដៅទី១ ៩៩% និង ៩៨% សម្រាប់គោលដៅទី២ និងទី៣។
- សង្ខេបស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាឆ្នាំ២០២២នេះ បានបង្ហាញថាៈ តាមការប៉ាន់ប្រមាណតាមបែបវិទ្យាសាស្ត្រ ក្នុងឆ្នាំ២០២៣ មានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ ៧៦,០០០នាក់ អ្នកឆ្លងថ្មីប្រមាណជា ១,៤០០នាក់ និងអ្នកស្លាប់ដោយមេរោគអេដស៍ ១,១០០នាក់។ មកដល់ពេលនេះ មានអ្នកផ្ទុកមេរោគអេដស៍ មកទទួលសេវាថែទាំជំងឺអេដស៍ ចំនួន ៦៤,៩៣២នាក់ ។
- នៅក្នុងចំណោមអ្នកឆ្លងថ្មីមាន៨២%ជាក្រុមប្រជាជនគន្លឹះ និងដៃគូរួមភេទរបស់ពួកគេ។ អត្រាប្រេវ៉ាឡង់នៃក្រុមប្រជាជនគន្លឹះ ស្ត្រីបម្រើសេវាកម្សាន្តមាន៤,៩% បុរសរួមភេទជាមួយនឹងបុរស ៤,0% ក្រុមបំប្លែងភេទមាន៩,៦% ក្រុមប្រើប្រាស់គ្រឿងញៀនដោយជក់៥,៧% ក្រុមប្រើប្រាស់គ្រឿងញៀនដោយចាក់១៥,២% ដែលអត្រានេះមានកម្រិតខ្ពស់ បើធៀបនឹងអត្រាប្រេវ៉ាឡង់នៃប្រជាជនដែលមានតែ០,៦%។ ការឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមស្ត្រីថយចុះគួរឱ្យកត់សំគាល់ ប៉ុន្តែការកើនឡើងក្នុងចំណោមបុរសស្រលាញ់បុរស។
- របាយនៃការប៉ាន់ប្រមាណការឆ្លងមេរោគអេដស៍ថ្មីឆ្នាំ២០២២ ៨៣% នៃអ្នកឆ្លងថ្មីជាប្រជាជនគន្លឹះ និង អតិថិជនរួមនឹងដៃគូ៤០% ចំណោមបុរសរួមភេទជាមួយបុរស១៥% ចំណោមអ្នករកស៊ីផ្លូវភេទ១៤% អតិថិជន រួមនឹងដៃគូ។
- ភាគរយនៃចំណេះដឹងអំពីការការពារមេរោគអេដស៍ ក្នុងចំណោមយុវវ័យទាំង២ភេទ អាយុពី ១៥-២៤ ឆ្នាំ មានកម្រិតទាប
- សកម្មភាព និងលទ្ធផលនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ធៀបនឹងសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៣៤

## ៥.៣ ក្រសួងទេសចរណ៍៖

-អនុវត្តគោលនយោបាយនៃការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងវិស័យទេសចរណ៍" ជូនដល់ម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ នារីផ្សព្វផ្សាយ និងអ្នកបម្រើការក្នុងវិស័យទេសចរណ៍បានចំនួន៣លើក មានអ្នកចូលរួមចំនួន២៥៨នាក់ ដែលប្រព្រឹត្តនៅទីរួមខេត្តស្វាយរៀង ក្រចេះ និងកំពត។

- បានចូលរួមប្រជុំពេញអង្គ ចំនួន១លើក

-បានចូលរួមបច្ចេកទេសជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន ១០លើក

## ៥.៤ ក្រសួងអប់រំ យុវជន និងកីឡា អប់រំផ្សព្វផ្សាយយុវវ័យក្នុងគ្រឹះស្ថានសិក្សា៖

- ដាក់បញ្ចូលការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ ជំងឺអេដស៍ទៅក្នុងក្របខណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការថវិកាកម្មវិធី និងផែនការប្រតិបត្តិប្រចាំឆ្នាំ។
- បានដាក់បញ្ចូលខ្លឹមសារមេរៀនស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ អត្តសញ្ញាភេទ និងយេនឌ័រ ក្រុមនិន្នាការផ្លូវភេទផ្សេងៗ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាអប់រំសុខភាពសម្រាប់ចំណេះទូទៅពីថ្នាក់ទី៥ ដល់ទី១២ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។
- បានបោះពុម្ពសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាពសម្រាប់ថ្នាក់ទី៧ ទី៨ ទី៩ និងទី១០ ចំនួនជាង ៨ម៉ឺនក្បាល ចែកជូនដល់គ្រូបង្រៀនទូទាំងប្រទេស។
- បានធ្វើបរិវត្តកម្មឌីជីថលខ្លឹមសារមេរៀនសៀវភៅសិក្សាគោលមុខវិជ្ជា អប់រំសុខភាពផ្តោតលើសមាសភាគសុខភាពផ្លូវភេទ សុខភាពបន្តពូជ សម្រាប់ថ្នាក់ទី៧ និងទី១០ និងបានផ្សព្វផ្សាយតាម បណ្តាញសង្គម ផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- បានបង្កើតអែប (App) សុខភាពយុវជន ដោយមានយុវជនចូលមើលជាង៤ម៉ឺននាក់។
- បានបង្កើតវីដេអូអប់រំខ្លីបែបជីវចល ដើម្បីគាំទ្រការរៀននិងបង្រៀនពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងបានផ្សព្វផ្សាយតាមបណ្តាញសង្គមផ្លូវការរបស់ក្រសួង។
- បានធ្វើសិក្ខាសាលាផ្សព្វផ្សាយអប់រំដល់ក្រុមប្រឹក្សាយុវជន យុវជនកាកបាទក្រហម និងយុវជនកាយរិទ្ធ ស្តីពីការអប់រំបង្ការការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ផលិតផលថ្នាំជក់បារីអេឡិចត្រូនិក និងការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ និងការបង្ការគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅខេត្តចំនួន១០ រួមមាន ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កំពត បាត់ដំបង បន្ទាយមានជ័យ ត្បូងឃ្មុំ ព្រៃវែង ព្រះសីហនុ និងខេត្តកំពង់ធំ ដោយមានអ្នកចូលរួមសរុបចំនួន ២៣៦៨នាក់ (ស្រី១៣៥៦នាក់)។
- បានបំប៉នគ្រូពីការប្រើប្រាស់សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាពសម្រាប់បឋមសិក្សាចំនួន ៣៦៩នាក់ ស្រី១៥៩នាក់ និងសម្រាប់មធ្យមសិក្សាចំនួន៩៥៣នាក់ ស្រី៥២៨នាក់ នៅខេត្ត

គោលដៅចំនួន៩ រួមមានរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ កំពត ឧត្តរមានជ័យ កំពង់ចាម និងខេត្តត្បូងឃ្មុំ។

**៥.៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖**

- អប់រំផ្សព្វផ្សាយដល់កម្មករ និយោជិតស្តីពីមេរោគអេដស៍ ផលប៉ះពាល់គ្រឿងញៀន លក្ខខណ្ឌការងារ វិធានអនាម័យ សន្តិសុខការងារនៅតាមសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ផ្នែកសាវ៉ាកម្សាន្ត ដល់កម្មករ និយោជិត ជនបង្គោល មិត្តអប់រំមិត្ត ប្រតិភូបុគ្គលិក មេឃុំ ជំទប់ ក្រុមប្រឹក្សាឃុំ ជំទប់ សមាជិកភូមិ និងប្រជាពលរដ្ឋដែលបានត្រឡប់មកពីក្រៅប្រទេស។
- សមាគមន៍នារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ បានអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ និងផលប៉ះពាល់គ្រឿងញៀនដល់ជនបង្គោល មិត្តអប់រំមិត្ត កម្មករនិយោជិត នៅតាមសហគ្រាស។

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) បង្កើន និងពង្រីកតំបន់គ្របដណ្តប់នៃសេវា PrEP។
- គាំទ្រការដាក់ចេញនូវគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២៤-២០២៨ មាន៖
  -គោលនយោបាយ ១៖ ពង្រឹងប្រព័ន្ធជាតិសម្រាប់ការឆ្លើយតបជាពហុវិស័យ
  -គោលនយោបាយ ២៖ ពង្រឹង ពង្រីក និងកែលម្អផ្នែកបង្ការ
  -គោលនយោបាយ ៣៖ ពង្រឹង ពង្រីក និងកែលម្អផ្នែកថែទាំ និងព្យាបាល
  -គោលនយោបាយ ៤៖ ពង្រឹង ពង្រីក និងកែលម្អផ្នែកគាំពារសង្គម
  -គោលនយោបាយ ៥៖ បញ្ចប់ការមាក់ងាយ និងរើសអើង
  -គោលនយោបាយ ៦៖ ចលនា ប្រភពធនធាន

**៥.៦ សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ទូលំទូលាយ និងជាពហុវិស័យលើកទី៦**

- ចក្ខុវិស័យ៖ ប្រជាជនកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងទទួលបានសិទ្ធិពេញលេញ ដោយគ្មានមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងគ្មានការមាក់ងាយ និងរើសអើង។
- បេសកម្ម៖ ធានាឱ្យមានការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាពហុវិស័យដែលមានការសម្របសម្រួលយ៉ាងល្អ រួមបញ្ចូលមូលដ្ឋាន សហគមន៍ និងក្រុមប្រជាជនប្រឈមមុខខ្ពស់ប្រកបដោយនិរន្តរភាព។
- ទស្សនៈវិស័យ៖ ប្រជាជនកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងផលិតភាពល្អ មានសិទ្ធសេរីភាព គ្មានការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍។
- ទិសដៅ៖ ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាពហុវិស័យ និងចិរភាព លែងមានការគំរាមកំហែងសុខភាពសាធារណៈត្រឹមឆ្នាំ២០២៨។

- មានគោលការណែនាំ៖
  - ភាពជាអ្នកដឹកនាំសហគមន៍ និងភាពជាម្ចាស់។
  - សមស្របជាមួយគោលនយោបាយជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព។
  - ហិរញ្ញប្រទានប្រកបដោយនិរន្តរភាព។
  - កិច្ចសហការ ប្រត្តិបត្តិការគ្រប់វិស័យ។
  - សមធម៌ និងផ្អែកតម្រូវការរបស់ប្រជាពលរដ្ឋ។
  - សមភាពយ៉េនឌ័រ។
  - ការចូលរួមរបស់សង្គមស៊ីវិល។
  - បទអន្តរាគមន៍ ផ្អែកលើភស្តុតាង។

**៥.៧ ទាក់ទងនឹងយន្តការ ការរើសអើង ម៉ាក់ងាយចំពោះក្រុមប្រឈម**

- បានរៀបចំផែនការសកម្មភាពដោយគ្របដណ្តប់ទៅលើ វិស័យ៣ផ្នែកមាន វិស័យអប់រំ វិស័យសុខាភិបាល និងសហគមន៍។
- ផ្អែកលើផែនការសកម្មភាព បានកំណត់សកម្មភាពអាទិភាពមួយចំនួន ដោយសារថវិកាមានកំណត់ឆ្នាំ២០២៣ បានកំណត់៖
  - ការរៀបចំយន្តការឆ្លើយតបនឹងការរើសអើង ការមាក់ងាយមានសកម្មភាពទាក់ទងសេវាបង្ការ សេវា PrEP STI ការធ្វើតេស្ត ការថែទាំ ប្រព័ន្ធគាំពារសង្គម ការមាក់ងាយ និងការរៀសអើង ។
  - សមភាពក្នុងការទទួលបានសេវាធ្វើតេស្ត និងព្យាបាលមេរោគអេដស៍ ដោយសារការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍ (HIVSD) នៅតែមាន។
  - ប្រជាជនសំខាន់ៗ (KPs) បានប្រឈមមុខនឹងការមាក់ងាយ និងការរើសអើងស្រដៀងគ្នានៅក្នុងការកំណត់ផ្សេងៗគ្នា ដូចជាការត្រូវគេធ្វើបាបនៅសាលារៀន និងអំពើហិង្សាក្នុងគ្រួសារ និងផ្លូវភេទចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។
  - ប្រទេសកម្ពុជាបានទទួលស្គាល់ថាការដោះស្រាយបញ្ហាសិទ្ធិមនុស្ស យេនឌ័រ និងជាពិសេសការមាក់ងាយ និងការរើសអើង គឺជាគន្លឹះក្នុងការបញ្ចប់វិសមភាព និងជំងឺអេដស៍នៅឆ្នាំ២០៣០។
- អ្វីជារបាយការណ៍ការរើសអើង និងការរើសអើងទាក់ទងនឹងមេរោគអេដស៍របស់ប្រទេសកម្ពុជា?
  - យន្តការរាយការណ៍ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បង្កើតនៅលើ CLM ដែលមានស្រាប់ដែលកំពុងត្រូវបានអនុវត្តដោយ FoNPAM/DFoNPAM។
  - បន្ថែមសំណួរ ("តើអ្នកបានរាយការណ៍ពីឧប្បត្តិហេតុនេះពីមុនទេ? កន្លែងណា?" និង "លេខទំនាក់ទំនងរបស់អ្នក") នៅក្នុងការស្ទង់មតិ CLM 7 ដែលផ្តោតលើការមាក់ងាយនិងការរើសអើង និងមុខងារជូនដំណឹងអំពីពាក្យបណ្តឹង។
  - តើអ្នកណាអាចដាក់ពាក្យបណ្តឹងការរើសអើង និងរើសអើងដែលទាក់ទងនឹងមេរោគអេដស៍?

- មេរោគអេដស៍ និងក្រុមអ្នកប្រឈមមុខខ្ពស់
  - បុគ្គលដែលមានផ្ទុកមេរោគអេដស៍ និងក្រុមអ្នកប្រឈមមុខខ្ពស់ អាចស្កេនការស្ទង់មតិ CLM 7 កូដ(QR)ដោយប្រើឧបករណ៍ចល័តរបស់ពួកគេ ដើម្បីដាក់ពាក្យបណ្ដឹងសម្រាប់ការស៊ើបអង្កេត និងផ្តល់ការយល់ព្រមដើម្បីទទួលបានការតាមដានលើលទ្ធផលស៊ើបអង្កេត និងសកម្មភាពដែលបានធ្វើឡើង។
  - ក្នុងរយៈពេល៦ខែ គិតចាប់ពីថ្ងៃដែលដើមបណ្ដឹងបានដឹងអំពីការមាក់ងាយ និងការរើសអើងដែលត្រូវបានចោទប្រកាន់។
- សមាសភាពក្រុមឆ្លើយតបដែលបានស្នើឡើង
  - ក្រុមឆ្លើយតបមេរោគអេដស៍ថ្នាក់ជាតិ FoNPAM (លេខាធិការដ្ឋាន), អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍, មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងមហាផ្ទៃ និង CPN+ និងដៃគូពាក់ព័ន្ធ
  - ក្រុមឆ្លើយតបមេរោគអេដស៍ខេត្ត DFoNPAM (លេខាធិការដ្ឋាន), គណៈកម្មាធិការជំងឺអេដស៍ខេត្ត (ប្រធាន),កម្មវិធីជំងឺអេដស៍ និងកាមរោគខេត្ត មន្ទីរសុខាភិបាលខេត្ត, មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សាលាខេត្ត និងនគរបាល។
- ពិចារណាសំខាន់ៗផ្សេងទៀត
  - ភាពសម្ងាត់ និងការភ័យខ្លាចនៃការសងសឹក។
  - ការលើកកម្ពស់ការរើសអើងដែលទាក់ទងនឹងមេរោគអេដស៍ និងការរាយការណ៍អំពីការរើសអើង និងយន្តការឆ្លើយតប។
  - ការរក្សាឯកសារ និងការកត់ត្រា។
  - ការតម្រង់ទិស និងផ្តល់សមត្ថភាពដល់ក្រុមឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
  - ការតាមដានការរើសអើងដែលទាក់ទងនឹងមេរោគអេដស៍ និងការរើសអើង ការឆ្លើយតបក្រុម និងការប្រើប្រាស់ទិន្នន័យ។

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** បានធ្វើការបញ្ជាក់ថា ការប៉ាន់ប្រមាណថាមានអ្នកឆ្លងមេរោគអេដស៍ថ្មី ក្នុងឆ្នាំ២០២៣ ដែលមានន័យថា មនុស្សប្រហែល៤នាក់ បានឆ្លងមេរោគអេដស៍ជារៀងរាល់ថ្ងៃ។ ការឆ្លងមេរោគអេដស៍ថ្មីត្រូវបានកាត់បន្ថយចំនួន៩១% ចាប់តាំងពីការរីករាលដាលនៃមេរោគអេដស៍ខ្ពស់បំផុតក្នុងឆ្នាំ១៩៩៦ ប៉ុន្តែល្បឿននៃការធ្លាក់ចុះបាននឹងកំពុងធ្លាក់ចុះ ហើយមានការថយចុះតែ ៣៣% បើធៀបនឹងឆ្នាំកន្លងមក។ ការប៉ាន់ស្មានមេរោគអេដស៍ថ្មី បានបង្ហាញថា ការកើនឡើងសមាមាត្រនៃការឆ្លងមេរោគអេដស៍ថ្មី គឺស្ថិតក្នុងចំណោមបុរស និងក្មេងប្រុស ពួកគេមានចំនួន ៧៩% នៃការឆ្លងមេរោគអេដស៍ថ្មីទាំងអស់ក្នុងឆ្នាំ២០២២។ តាមចំនួនប្រជាជន៨៣% នៃការឆ្លងមេរោគអេដស៍ថ្មី សរុបគឺស្ថិតក្នុងចំណោមប្រជាជនគន្លឹះ បុរសរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកដែលប្រើប្រាស់និងចាក់ថ្នាំញៀន និងដៃគូផ្លូវ

ភេទរបស់ពួកគេ ។ សមិទ្ធិផលរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាគំរូ ក្នុងការសម្រេចបានខ្ពស់បំផុតនូវអត្រាទទួលសេវាព្យាបាល និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។ គិតត្រឹមខែធ្នូ ឆ្នាំ២០២២ អ្នកផ្ទុកមេរោគអេដស៍ ៦៤.៩៣១នាក់ បានកំពុងទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ហើយវាប្រែថា៩៩% នៃអ្នកផ្ទុកមេរោគអេដស៍ ដែលដឹងពីស្ថានភាពរបស់ពួកគេ កំពុងទទួលបានការព្យាបាល ហើយ៩៨% នៃអ្នកផ្ទុកមេរោគអេដស៍ លើការព្យាបាលត្រូវបានកាត់បន្ថយមេរោគមកកម្រិតទាបបំផុត។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកនូវសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើង៖

១. កែតម្រូវបន្ថែមនូវជាតុចូលមួយចំនួនទាក់ទងនឹងសេចក្តីព្រាងរបាយការណ៍ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងចំគោលដៅ ព្រមទាំងឧបសគ្គដែលត្រូវដោះស្រាយ និងលើកសំណើជូនថ្នាក់ដឹកនាំនៅក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ខាងមុខ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការ ប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ថ្ងៃសុក្រ ១២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣

| | | |
|---|---|---|
| | **បានពិនិត្យត្រឹមត្រូវ** | អ្នកធ្វើរបាយការណ៍ |
| **ប្រធានអង្គប្រជុំ** | **ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន** | |
| **បណ្ឌិត ឈឹម យិនដារ៉េត** | | **ស៊ុំ ផល្លា** |